## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ១៨ .-** ចំនួនដំបូងនៃក្របខ័ណ្ឌ ត្រូវកំណត់ចេញពីសមាសភាពនៃមន្ត្រីរាជការទាំងឡាយក្នុងមុខតំណែង ហើយដែលកំពុងបំពេញមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅតាមរដ្ឋបាលកណ្តាល និងតាមខេត្ត-ក្រុង ។ គោលការណ៍នៃការផ្ទេរបញ្ចូលមន្ត្រីរាជការ ទៅក្នុងក្របខ័ណ្ឌថ្មី ត្រូវកំណត់បញ្ជាក់ដោយអនុក្រឹត្យ ។

និស្សិតថ្នាក់មធ្យមជំនាន់ទី១នៃសាលាភូមិន្ទរដ្ឋបាលមួយចំនួន ដែលបានទទួលជោគជ័យក្នុងការប្រឡងចេញនៅខែកុម្ភៈ ឆ្នាំ១៩៩៩ ត្រូវបានទទួលអត្ថប្រយោជន៍ ខាងក្រោម :

- និស្សិតដែលមានសញ្ញាប័ត្រមធ្យមសិក្សាកម្រិត២ បូក ២ នៅពេលប្រឡងចូល ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៣ ឋានន្តរស័ក្តិទី៣ នៃប្រភេទ ក ក្រោយការបញ្ចប់ការសិក្សា ។
- និស្សិតដែលមានសញ្ញាប័ត្រមធ្យមសិក្សាកម្រិត២ បូក ៤ នៅពេលប្រឡងចូល ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១២ ឋានន្តរស័ក្តិទី៣ នៃប្រភេទ ក ក្រោយការបញ្ចប់ការសិក្សា ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ១៩ .-** នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ២០.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និង តាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

***

## អនុក្រឹត្យលេខ ១០ អនក្រ.បក

## ស្តីពី

## ការកែសម្រួល អត្រាពន្ធលើទំនិញ នាំចូល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩
- បានឃើញសេចក្តីសម្រេចលេខ ០០២/សសរ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ១៩៩៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រើប្រាស់តារាងពន្ធគយ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមស្មារតីអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩
- ផ្អែកតាមសភាពការណ៍ចាំបាច់ និង ជាបន្ទាន់

**សំរេច**

មាត្រា ១ .- បន្ទាត់ពន្ធទំនិញមួយចំនួន ដែលមានក្នុងតារាងពន្ធគយ ត្រូវកែសម្រួលដូចខាងក្រោមនេះ ៖

| លេខសំគាល់ | ចាស់ | | | | កែសម្រួល | | | |
|---|---|---|---|---|---|---|---|---|
| | DD | TC | TE | ការយោង | DD | TC | TE | ការយោង |
| 2207.00.00 | ហាមឃាត់នាំចូល | | | | ហាមឃាត់នាំចូល | | | |
| 1902.30.10 | 7% | 4% | រ.ព | (1) | 15% | 4% | រ.ព | (1) |
| 2501.00.91 | 15% | 4% | រ.ព | (1) | 35% | 4% | រ.ព | (1) |
| 2523.00.00 | 7% | 4% | រ.ព | (1) | 15% | 4% | រ.ព | (1) |
| 3917.00.00 | 7% | 4% | រ.ព | (1) | 15% | 4% | រ.ព | (1) |
| 3923.00.00 | 7% | 4% | រ.ព | (1) | 15% | 4% | រ.ព | (1) |
| 4011.20 | 15% | 4% | រ.ព | (1) | 15% | 4% | រ.ព | (1) |
| 4011.50.00 | 7% | 4% | រ.ព | (1) | 15% | 4% | រ.ព | (1) |
| 4013.10.00 | 15% | 4% | រ.ព | (1) | 35% | 4% | រ.ព | (1) |

www.pheakdeylaw.com

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 4013.20.00 | 7% | 4% | រ.គ | (1) | 15% | 4% | រ.គ | (1) |
| 6904.00.00 | 7% | 4% | រ.គ | (1) | 15% | 4% | រ.គ | (1) |
| 6905.00.00 | 7% | 4% | រ.គ | (1) | 15% | 4% | រ.គ | (1) |
| 7210.00.00 | 7% | 4% | រ.គ | (1) | | | | |
| 7210.31.10 | - | - | - | - | 15% | 4% | រ.គ | (1) |
| 7210.41.00 | - | - | - | - | 15% | 4% | រ.គ | (1) |
| 7212.00.00 | 7% | 4% | រ.គ | (1) | | | | |
| 7212.21.00 | - | - | - | - | 15% | 4% | រ.គ | (1) |
| 7905.00.00 | 7% | 4% | រ.គ | (1) | | | | |
| 7905.10.00 | - | - | - | - | 15% | 4% | រ.គ | (1) |

១៩០២.៣០.១០ មីសួ . មីកញ្ចប់

២២០៧.០០.០០ អាល់កុលអេទីលិកមិនបានបំប្លែងធម្មជាតិកម្រិត ៨០% ឬលើស នៃឯកតាចំណុះ ។ អាល់កុលអេទីលិក និងស្រាដែលបានបំប្លែងធម្មជាតិ

២៥០១.០០.៩១ អំបិលសំរាប់មនុស្សបរិភោគ

២៥២៣.០០.០០ ស៊ីម៉ង់ត៍" ស្រូបទឹក " រាប់បញ្ចូលទាំងស៊ីម៉ង់ត៍មិនទាន់កិនទោះពីរោងការ ពណ៌ក៏ដោយ

៣៩១៧.០០.០០ ទីប បំពង់ និងគ្រឿងបន្លាស់ផ្សេងៗរបស់វា (តំណ កែង ... ជាឧទាហរណ៍) ធ្វើពីវត្ថុធាតុផ្លាស្ទិក

៣៩២៣.០០.០០ ប្រដាប់សំរាប់ដឹកជញ្ជូន ឬ វេចខ្ចប់ធ្វើពីផ្លាស្ទិក ថង់ ធុង ដប និងរបស់របរសំរាប់បិទដែលធ្វើអំពីផ្លាស្ទិក ។

៤០១១.២០.០០ សំបកកង់ថ្មីសំរាប់រថយន្តដឹកអ្នកដំណើរ ឬ ដឹកទំនិញធ្វើពី កៅស៊ូ ។

៤០១១.៥០.០០ សំបកកង់ថ្មីសំរាប់ទោចក្រយាន

៤០១៣ ពោះវៀនកង់ធ្វើអំពីកៅស៊ូ

៤០១៣.១០.០០ នៃប្រភេទសំរាប់រថយន្តទេសចរណ៍" ដោយរួមទាំងប្រភេទ ស្រ៊ិត break និងរថយន្តប្រណាំងផង" សំរាប់រថយន្តដឹកអ្នកដំណើរ និង ដឹកទំនិញ ។

៤០១៣.២០.០០ នៃប្រភេទសំរាប់ប្រើទោចក្រយាន

៦៩០៤.០០.០០ ឥដ្ឋសំណង់សំណង់ក្បឿង Houris, cache-poutrelles និង របស់របរប្រហាក់ប្រហែលធ្វើពីសេរ៉ាមិច

| | |
|---|---|
| ៦៩០៥.០០០០ | ក្បឿង គ្រឿងប្រដាប់បំពង់ផ្សែង បំពង់ផ្សែង គ្រឿងលំអខាងស្ថាបត្យកម្ម ធ្វើពីសេរ៉ាមិក និង គ្រឿងប្រដាប់ដទៃទៀតនៃអគារ |
| ៧២១០០០.០០ | ផលិតផលរមិលរាបស្មើពីដែក ឬ ពីដែកថែបគ្មានល្បាយដែលមានទទឹង ៦០០ម.ម ឬ លើស ស្រោបលាប ឬ ស្រោប |
| | - ស្រោបលាបសំណប៉ាហាំងតាមវិធីអេឡិចត្រូលីទិក: |
| | - អំពីដែកដែលមានកំរាស់តិចជាង ៣ម.ម និងដែលមានភាពយឺតអប្ប-បរមា ២៥៧MPa ឬ កំរាស់ ៣ម.ម ឡើងទៅ និង មានកំរិតភាពយឺតអប្បបរមា ៣៥៥MPa |
| ៧២១០.៣១១០ | -----ដែលមានរាងជាទីការ៉េ |
| | - ដែលស្រោបលាបសំណប៉ាហាំងតាមវិធីផ្សេងទៀត : |
| ៧២១០.៤១.០០ | -- ដែលមានរាងជាទីការ៉េ |
| ៧២១២.០០. | ផលិតផលរមិលរាបស្មើពីដែក ឬ ពីដែកថែបគ្មានល្បាយដែលមានទទឹង ក្រោម ៦០០ម.ម ស្រោបលាប ឬ ស្រោប |
| | -ស្រោបលាបសំណប៉ាហាំងតាមវិធីអេឡិចត្រូលីទិក |
| ៧២១២.២១.០០ | -- អំពីដែកថែបដែលមានកំរាស់តិចជាង ៣ម.ម និងមាន កំរិតភាពយឺតអប្បបរមា ២៧៥MPa ឬ កំរាស់ ៣ម.ម ឬ លើស និងមានកំរិតភាពយឺតអប្បបរមា ៣៥៥MPa |
| ៧២១២.២១.១០ | --- ដែលមានរាងជាទីការ៉េ |
| ៧៩០៥.០០.០០ | តួល បន្ទះគម្រឹកស័ង្កសី (ពីសំណប៉ាហាំង) |
| ៧៩០៥.១០.០០ | - រាងជាទីការ៉េ |

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ សហរដ្ឋមន្ត្រីទទួលបន្ទុកគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង ក្រសួង-ស្ថាប័នពាក់ព័ន្ធមានភារកិច្ច អនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

www.pheakdeylaw.com